**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង រវាង

**នៃក្រុមហ៊ុន ផាភីលៀន ថេកស្ដាយ (ខេមបូឌា)ខូអិលធីឌី**

**និង**

**ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក**

**នៃក្រុមហ៊ុន ផាភីលៀន ថេកស្ដាយ (ខេមបូឌា)ខូអិលធីឌី**

**ស្ដីពី**

**ការផ្ដល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ**

**ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារបញ្ហាកង្វះវត្ថុធាតុដើម និងមិនមានអ្នកបញ្ជាទិញ**

ឆ្នាំពីរពាន់ម្ភៃបី ខែឧសភាថ្ងៃទី០៥ វេលាម៉ោង ១៥:០០ រសៀល នៅក្នុងការិយាល័យរដ្ឋបាលក្រុមហ៊ុន ផាភីលៀន ថេកស្ដាយ(ខេមបូឌា)ខូអិលធីឌី ដែលមានអាសយដ្ឋានស្ថិតនៅផ្លូវជាតិលេខ៣ ភូមិព្រៃសំព័រ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានរៀបចំការប្រជុំមួយរវាងក្រុមហ៊ុន ផាភីលៀន ថេកស្ដាយ(ខេមបូឌា)ខូអិលធីឌី និងប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកប្រចាំក្រុមហ៊ុន។

ក្នុងអង្គប្រជុំ ប្រធានផ្នែករដ្ឋបាល បានមានមតិស្វាគមន៍ និងសំណេះសំណាលជាមួយបងប្អូនប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព និងប្រធានក្រុមគ្រប់ផ្នែក ក្នុងអង្គប្រជុំនោះផងដែរ ប្រធានផ្នែករដ្ឋបាលបានជម្រាបជូនតំណឹងដល់បងប្អូនប្រតិភូបុគ្គលិក (តំណាងកម្មករ) និងតំណាងសហជីព ប្រធានក្រុមគ្រប់ផ្នែកទាំងអស់ អំពីស្ថានភាពបច្ចុប្បន្នដែលប្រឈមមុខយ៉ាងខ្លាំងនូវបញ្ហាកង្វះវត្ថុធាតុដើម និងមិនទាន់មានអ្នកបញ្ជាទិញ ដែលជាមូលហេតុធ្វើអោយសង្វាក់ផលិតកម្មមិនអាចដំណើរការឲ្យបងប្អូនកម្មករនិយោជិតបានធ្វើការងារពេញលេញឡើយ។ ហេតុដូចច្នេះថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនបានសម្រេចចិត្តព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន ....៩៦៦...នាក់ ស្រី...៨៤២...នាក់ ក្នុងចំណោមកម្មករសរុប...១២៣៣..នាក់ រយៈពេល ១៤ ថ្ងៃ គឺចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២៣ និងចូលមកធ្វើការវិញនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៣ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ បងប្អូនកម្មករនិយោជិតបានយល់ព្រម និងឯកភាពទទួលយកប្រាក់ឧបត្ថម្ភរបស់ក្រុមហ៊ុនតាមលក្ខខណ្ឌដូចខាងក្រោម៖

១.ភាគីក្រុមហ៊ុន ឯកភាពផ្ដល់ប្រាក់ឧបត្ថម្ភចំនួន $15 (ដប់ប្រាំដុល្លា) ក្នុងកំឡុងពេលព្យួរ និងកំណត់បើកជូនបងប្អូនកម្មករនិយោជិតនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៣។

កិច្ចប្រជុំនេះ បានបញ្ចប់នៅវេលាម៉ោង ១៥:៣០ រសៀលនាថ្ងៃខែឆ្នាំដដែល ក្រោមកិច្ចព្រមព្រៀងគ្នាដោយស្មារតីយោគយល់គ្នា សហការគ្នា និងការទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២៣

**ហត្ថលេខា និងត្រានាយកក្រុមហ៊ុន**

PAPILLION TEXTILE (CAMBODIA) CO., LTD

LIEU VILUAN

## ស្នាមមេដៃ ប្រតិភូបុគ្គលិក (តំណាងកម្មករ) តំណាងសហជីព

| | |
|---|---|
| ១.លោកស្រី ណាន ឡុន | ១០.លោក សែម សារ៉ូត |
| ២. លោកស្រី រុន សំភី | ១១.អ្នកនាង ឡូញ ចាន់ថា |
| ៣.លោកស្រី វែង សុខា | ១២.លោកស្រី ឡុញ វន្នី |
| ៤.លោក គូ គាំ | ១៣.លោក គង់ សោភ័ណ្ឌ |
| ៥.លោកស្រី សាន សុខលី | ១៤.លោក រិន គុយ |
| ៦.លោកស្រី ហូ ស៊ីណាង | ១៥.អ្នកនាង អោម មិន |
| ៧.លោក ផល ស្តើង | ១៦.អ្នកនាង ផែន អូន |
| ៨. លោកស្រី ភួង ផល្លី | ១៧.អ្នកនាង យ៉ុង កញ្ញា |
| ៩. លោកស្រី ផល ចន្ទី | ១៨.អ្នកនាង អៀត សារូ |